# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

## ឧត្តមសេនីយឯក JOHN MURRAY SANDERSON, AC និង លោកស្រី LORRAINE SANDERSON ធ្វើទស្សនកិច្ចនៅកម្ពុជា

អតីតអគ្គមេបញ្ជាការ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ឯកឧត្តម ឧត្តមសេនីយ៍ឯក John Murray Sanderson AC និង លោកស្រី Lorraine Sanderson ជាភរិយា នឹងមកបំពេញទស្សនកិច្ចនៅកម្ពុជា ចាប់ពីថ្ងៃទី ២៣ ខែមេសា ដល់ថ្ងៃទី ២ ខែឧសភា ដើម្បីអបអរខួបទី ៣០ឆ្នាំ នៃអ៊ុនតាក់ និងជាផ្នែកមួយនៃការអបអរខួបទី ៧០ឆ្នាំនៃទំនាក់ទំនងការទូតរវាងអូស្ត្រាលី និងកម្ពុជា។

ក្នុងដំណើរទស្សនកិច្ចនេះ ឧត្តមសេនីយ៍ឯក Sanderson និងលោកស្រី Sanderson នឹងចូលគាល់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា។

ឧត្តមសេនីយ៍ឯក Sanderson និងលោកស្រី Sanderson ក៏នឹងជួបជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ព្រមទាំងជួបជាមួយ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី អភិបាលខេត្ត មន្ត្រីសំខាន់ៗ និងតំណាងសង្គមស៊ីវិលផងដែរ។

កិច្ចប្រជុំទាំងនេះផ្តល់ឱកាសដើម្បីឆ្លុះបញ្ចាំងពីការរួមចំណែកផ្ទាល់ខ្លួន និងមិត្តភាព ដែលបានកសាងទំនាក់ទំនងដ៏រឹងមាំរវាងអូស្ត្រាលី និងកម្ពុជា ក្នុងរយៈពេល ៧០ឆ្នាំ កន្លងមកនេះ និងជួយបង្ហាញ ពីរបៀបដែលយើងអាចពង្រឹងទំនាក់ទំនងរបស់យើងបន្ថែមទៀត ទៅអនាគត។

ឧត្តមសេនីយឯក Sanderson នឹងបើកការតាំងពិពណ៌មួយ ដែលរៀបចំដោយស្ថានទូតអូស្ត្រាលី ជាមួយ មជ្ឈមណ្ឌលសិក្សាបណ្តុះបណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់ និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) ដើម្បីរំលឹកខួបលើកទី ៣០ឆ្នាំ នៃអ៊ុនតាក់ នៅសណ្ឋាគារ Raffles

Hotel Le Royal។ ពិព័រណ៍អ៊ុនតាក់នឹងបើកជូនដោយសេរីដល់សាធារណជន ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ ៩:០០ យប់ ជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី ២៩ ខែមេសា ដល់ ថ្ងៃទី២៨ ខែឧសភា។

អ៊ុនតាក់ ជាសម័យកាលប្រវត្តិសាស្ត្រមួយសម្រាប់ប្រទេសកម្ពុជា និងជាគំរូដ៏ល្អនៃកិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព ដែលប្រទេសជប៉ុន និងប្រទេសជាសមាជិកអាស៊ានមួយចំនួន បានរួមចំណែកសំខាន់ៗផងដែរ។ វាត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩២ ដើម្បីត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព របស់ប្រជាជនកម្ពុជា ដែលបានផ្លាស់ទីលំនៅដោយសង្គ្រាមស៊ីវិល និងការបោះឆ្នោតជាតិឆ្នាំ ១៩៩៣ ។ ឧត្តមសេនីយ៍ឯក Sanderson របស់អូស្ត្រាលីបានបញ្ជាកងកម្លាំងពហុភាគីដ៏ធំរបស់ខ្លួន ដែលមានកងវរសេនាតូចថ្មើរជើង និងអង្គភាពគាំទ្រ ចំនួន ១២ អ្នកសង្កេតការណ៍យោធា និងនគរបាលស៊ីវិល សរុបចំនួន ២២ ០០០ នាក់ មកពី ប្រហែល ៤០ ប្រទេសផ្សេងៗគ្នា។

បន្ថែមពីការផ្តល់បញ្ជាការផ្នែកយោធា អូស្ត្រាលីក៏បានផ្តល់បុគ្គលិកជាង ១ ២០០ នាក់ ដល់អ៊ុនតាក់ផងដែរ។ អូស្ត្រាលីបានផ្តល់ជំនួយដំបូង ដែលជាអង្គភាពទំនាក់ទំនងកម្លាំង ដែលមានបុគ្គលិក ៤៨៨ នាក់ ដោយភាគច្រើនមកពីកងវរសេនាធំសញ្ញាទី២ របស់កងទ័ពអូស្ត្រាលី។ កងនាវាចរទី២ រួមមានកងទ័ពជើងទឹកភូមិន្ទអូស្ត្រាលី កងទ័ពអាកាសភូមិន្ទអូស្ត្រាលី និង កងទ័ពរបស់ណូវ៉ែលហ្ស៊ីឡង់។ អ្នកផ្តល់សញ្ញាអូស្ត្រាលី (បុគ្គលិកទំនាក់ទំនង) បានបំពេញការងារជាប់ជាមួយនឹងអង្គភាពអ៊ុនតាក់ផ្សេងៗទៀត នៅទូទាំងប្រទេសកម្ពុជា ដើម្បីរក្សាទំនាក់ទំនងជាមួយទីបញ្ជាការកងកម្លាំង។ ឧត្តមសេនីយ៍ឯក Sanderson បានមានប្រសាសន៍ថា អ្នកផ្តល់សញ្ញាទាំងនោះគឺ "ជាការដែលភ្ជាប់បេសកកម្មជាប់ជាមួយគ្នា" ។

អូស្ត្រាលីជាមិត្ត ដៃគូ និងជាប្រទេសជិតខាង ដ៏យូរអង្វែងរបស់កម្ពុជា។ ខួបលើកទី៧០ឆ្នាំនៃទំនាក់ទំនងទ្វេភាគីរបស់យើង នៅឆ្នាំនេះ ជាឱកាសដ៏សំខាន់មួយ ដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់យើង ក្នុងកិច្ចសហប្រតិបត្តិការលើ វិស័យសុខាភិបាល កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនរបស់យើង រួមទាំងការរួមចំណែកដ៏សំខាន់របស់យើងចំពោះអ៊ុនតាក់។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au